ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៣៥..សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពនៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិ ដឹកនាំបញ្ហាការប្រយុទ្ធ និងទប់ស្កាត់អំពើភេរវកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៨/១៧២ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានចំណុះលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិដឹកនាំបញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម
- បានឃើញប្រកាសលេខ ១៨/០៨ គជបភ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ស្តីពីការបង្កើតការិយាល័យអង្គភាពចំណុះនាយកដ្ឋាននានានៃលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិដឹកនាំបញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម
- យោងតាមសំណើរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋានគណៈកម្មាធិការជាតិដឹកនាំបញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម

## សម្រេច

**ប្រការ ១:** - ត្រូវបានផ្លាស់ប្តូរសមាសភាព អនុប្រធាន និងសមាជិកលេខាធិការដ្ឋានគណៈកម្មាធិការជាតិដឹកនាំបញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម ដូចខាងក្រោម:

www.pheakdeylaw.com

១- ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន ជាអនុប្រធានលេខាធិការដ្ឋាន គជបភ ទទួលបន្ទុកលើកិច្ចការការពារហេដ្ឋារចនាសម្ព័ន្ធ ជំនួសឯកឧត្តម នាយឧត្តមសេនីយ៍ ហុក ឡុងឌី ដែលបានទទួលមរណភាព ។

២- ឧត្តមសេនីយ៍ទោ មៀច សុផាន់ណា ជាអនុប្រធានលេខាធិការដ្ឋាន គជបភ ជំនួសឯកឧត្តមឧត្តមសេនីយ៍ឯក មៅ ចន្ទ័តារា ។

៣- ឧត្តមសេនីយ៍ឯក អ៊ុក គីមលេខ ជាសមាជិកលេខាធិការដ្ឋាន និងជាប្រធានក្រុមហេដ្ឋាទី ៣ ជំនួស ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន ដែលត្រូវទទួលតួនាទី និងភារកិច្ចថ្មី ។

៤- ឧត្តមសេនីយ៍ត្រី ចាន់ គីមសេង ជាសមាជិកលេខាធិការដ្ឋាន គជបភ ជំនួសឯកឧត្តមឧត្តមសេនីយ៍ អ៊ុក គីមលេខ ដែលត្រូវទទួលតួនាទី និងភារកិច្ចថ្មី ។

**ប្រការ ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គណៈកម្មាធិការជាតិដឹកនាំបញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន លេខាធិការដ្ឋានគណៈកម្មាធិការជាតិដឹកនាំបញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្មគ្រប់អង្គភាពពាក់ព័ន្ធ និងសាម៉ីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com